# អនុស្សរណៈនៃការយោគយល់គ្នា
# ស្តីពីការចងសម្ព័ន្ធមេត្រីភាព
# រវាងខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា
# និងតំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន

ដោយយោងតាមគោលការណ៍រួម ស្តីពីការបង្កើតទំនាក់ទំនងការទូត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជា-មានិតចិន ខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា និងតំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន បានព្រមព្រៀងគ្នាបង្កើតនូវអនុស្សរណៈនៃការយោគយល់គ្នាស្តីពីចំណងមិត្តភាព កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការយោគយល់គ្នាដើម្បីផ្សព្វផ្សាយ វប្បធម៌ អរិយធម៌ និងលើកកម្ពស់ការអភិវឌ្ឍវិស័យផ្សេងៗក្នុងខេត្តទាំងពីរ ឱ្យកាន់តែមានការរីកចម្រើន។

ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមខ្លឹមសារដូចខាងក្រោម៖

I. គាំទ្រ និងជម្រុញលើវិស័យទេសចរណ៍ អប់រំ ពាណិជ្ជកម្ម និងវិនិយោគដើម្បីផលប្រយោជន៍ទៅវិញទៅមក សម្រាប់ភាគីទាំងពីរដោយអនុលោមទៅតាមច្បាប់ និងគោលការណ៍អនុញ្ញាតនៃរដ្ឋាភិបាលប្រទេសទាំងពីរ។

II. ធ្វើការផ្លាស់ប្តូរទៅវិញទៅមកនូវដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៃភាគីទាំងពីរ ដើម្បីចែករំលែកបទពិសោធន៍ និងស្វែងយល់នូវប្រវត្តិសាស្ត្រ វប្បធម៌ អរិយធម៌ ទេសចរណ៍ និងវិស័យផ្សេងៗទៀត ក្នុងគោលបំណងបង្កើនសមត្ថភាព ដល់មន្ត្រីរបស់ភាគីទាំងពីរឱ្យកាន់តែល្អប្រសើរ។

III. ផ្តល់ព័ត៌មានទៅវិញទៅមកទាក់ទងទៅនឹងវិស័យទេសចរណ៍ វិនិយោគ និងវិស័យផ្សេងៗទៀត សម្រាប់ការអភិវឌ្ឍរបស់ភាគីទាំងពីរ។

IV. ក្រោយពេលអនុស្សរណៈនៃការយោគយល់គ្នានេះចូលជាធរមាន ការិយាល័យកិច្ចការបរទេស និងទំនាក់ទំនងសាធារណៈ នៃតំបន់រដ្ឋបាលពិសេសម៉ាកាវ និងទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ នៃរដ្ឋបាលខេត្តសៀមរាប នឹងក្លាយជាដៃគូទំនាក់ទំនង និងសម្របសម្រួលរៀបចំការងារប្រជុំ និងទំនាក់ទំនងជាមួយផ្នែកផ្សេងៗ ដើម្បីជម្រុញដំណើរការនៃកិច្ចសហប្រតិបត្តិការលើវិស័យដែលបានកំណត់ខាងលើ។

V. អនុស្សរណៈនៃការយោគយល់គ្នានេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ក្នុងករណីធ្វើវិសោធនកម្ម បន្តនិងបញ្ចប់អនុស្សរណៈនៃការយោគយលគ្នានេះ ភាគីទាំងពីរនឹងពិភាក្សា និងធ្វើកំណត់ត្រាជាលាយ-លក្ខណ៍អក្សរ។

VI. អនុស្សរណៈនៃការយោគយល់គ្នានេះធ្វើជាបីភាសា គឺភាសាខ្មែរ ភាសាចិន និងភាសាអង់គ្លេស ហើយអត្ថបទទាំងបីភាសានេះ មានតម្លៃស្មើគ្នា។

ធ្វើនៅតំបន់រដ្ឋបាលពិសេសម៉ាកាវ ថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨។

**តំណាងតំបន់រដ្ឋបាលពិសេសម៉ាកាវ**
**នៃសាធារណរដ្ឋប្រជាមានិតចិន**

Mr. CHUI SAI ON
**នាយកប្រតិបត្តិតំបន់**

**តំណាងរដ្ឋបាលខេត្តសៀមរាប**
**នៃព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តមបណ្ឌិត ឃឹម ប៊ុនសុង**
**អភិបាលខេត្ត**